UNITED NATIONS
INDUSTRIAL DEVELOPMENT ORGANIZATION

german cooperation
DEUTSCHE ZUSAMMENARBEIT

# ស្ត្រីក្នុង ឧស្សាហកម្មបៃតង

## តើគោលនយោបាយយេនឌ័របែបផ្លាស់ប្តូរស៊ីជម្រៅ អាចជំរុញភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រីបានដោយរបៀបណា?

ឧស្សាហកម្មបៃតង លើកកម្ពស់ផលិតកម្មឧស្សាហកម្មប្រកបដោយនិរន្តរភាព ដោយមិនបំផ្លាញបរិស្ថាន ឬបង្កផលអាក្រក់ដល់សុខភាពមនុស្ស ព្រមទាំងផ្តល់ការងារសមរម្យដល់បុរសនិងស្ត្រី។ លំនាំនៃការផលិតនិងការប្រើប្រាស់ប្រកបដោយនិរន្តរភាព ជាលំនាំដែលប្រើប្រាស់ធនធាននិងថាមពលប្រកបដោយប្រសិទ្ធភាព បញ្ចេញកាបូននិងកាកសំណល់តិច មិនបំពុល ហើយមានសុវត្ថិភាព។

នៅក្នុងបរិការណ៍ប្រទេសកម្ពុជា ពាក្យ "ឧស្សាហកម្មបៃតង" មិនទាន់មាននិយមន័យច្បាស់លាស់នៅឡើយទេ។ ខណៈដែលព័ត៌មាននៅមានតិចតួច យើងបានពិនិត្យមើលលើវិស័យមួយចំនួន ដូចជាផ្នែកកាត់ដេរសម្លៀកបំពាក់, វាយនភ័ណ្ឌ និងស្បែកជើង ព្រមទាំងផ្នែកកសិឧស្សាហកម្ម, ថាមពល និងទេសចរណ៍ផងដែរ ដោយសារវាមានសក្តានុពលខ្ពស់សម្រាប់ទទួលស្គាល់ថាជាវិស័យ "បៃតង" និងផ្តល់ឱកាសច្រើនដល់ស្ត្រី។



តួនាទីតាមបែបវប្បធម៌ ឬប្រពៃណីរបស់ស្ត្រី និងភាពជិតស្និទ្ធរបស់គេជាមួយបរិស្ថាន មានឥទ្ធិពលទៅលើអ្វីដែលត្រូវបានយល់ឃើញថាជាភាពខ្លាំងរបស់ពួកគេ នៅក្នុងឧស្សាហកម្មបៃតង។

### តួនាទី "ថែទាំនិងចិញ្ចឹមបីបាច់" របស់ស្ត្រី

ដោយសារតែវាផ្តោតលើការថែទាំបរិស្ថានស្រាប់ ឧស្សាហកម្មបៃតងមានចរិតជាធម្មជាតិស្របគ្នាទៅនឹង "តួនាទីថែទាំ" របស់ស្ត្រីដែរ។

### បទពិសោធន៍ការងាររបស់ស្ត្រីសមតាមតម្រូវការ

វាងាយស្រួលជាងសម្រាប់ស្ត្រី ក្នុងការរកឱកាសការងារ នៅតាមវិស័យដែលខ្លួនធ្លាប់ធ្វើក្រៅប្រព័ន្ធស្រាប់(ឧទា. ផ្នែកកសិកម្ម និងការគ្រប់គ្រងធនធានធម្មជាតិ)។

%

សូចនាករសំខាន់ៗមួយចំនួនបានបង្ហាញផងដែរអំពីសក្តានុពលខ្ពស់សម្រាប់សមភាពយេនឌ័រ និងការធ្វើបដិវត្តកម្មសង្គម នៅក្នុងឧស្សាហកម្មបៃតង។

**៥៤%**

នៃសហគ្រិនស្ត្រីនិយាយថាធ្លាប់ទទួល "ការជួយជ្រោមជ្រែងច្រើន" ពីក្រុមគ្រួសាររបស់ខ្លួនក្នុងការចាប់ផ្តើមធុរកិច្ចបៃតង។

**៥៨%**

នៃសហគ្រិនស្ត្រីក្នុងឧស្សាហកម្មបៃតងនិយាយថាធ្លាប់បានដឹងអំពីគោលនយោបាយ និងកម្មវិធីនានាដែលលើកទឹកដល់ពួកគេឱ្យបើកអាជីវកម្ម។

**៦២%**

នៃសហគ្រិនបៃតងនិយាយថាពួកគេ "មានក្តីរំភើបខ្លាំង ឬគួរសមដែរ" ដោយឃើញថាអាជីវកម្មរបស់ខ្លួននឹងរីកចម្រើនឡើង។

**៧០%**

នៃសហគ្រិនស្ត្រីនិយាយថាធ្លាប់មានដៃគូដែល "ជួយជ្រោមជ្រែង ឬជួយជ្រោមជ្រែងខ្លាំង" នៅក្នុងការខិតខំប្រកបអាជីវកម្មសហគ្រិនបៃតង។

**៧៧%**

នៃធុរកិច្ចបៃតងផ្តល់កម្រៃស្មើគ្នាសម្រាប់ការងារដូចគ្នា ចំពោះបុរសនិងស្ត្រី។

**អ្នកផ្តល់សម្ភាសន៍និយាយថា ស្ត្រីមានឱកាសកាន់តែច្រើននៅក្នុងឧស្សាហកម្មបៃតង ជាងនៅក្នុងឧស្សាហកម្មបែបប្រពៃណី។**

មានឱកាសកាន់តែច្រើនសម្រាប់ភាពរីកចម្រើននិងភាពជឿនលឿន ដោយសារឧស្សាហកម្មបៃតងមិនសូវរងឥទ្ធិពលពីទស្សនៈលម្អៀងផ្នែកយេនឌ័រទេ

បច្ចេកវិទ្យាកំពុងលុបបំបាត់នូវភាពចាំបាច់ជាប្រពៃណីថា ត្រូវតែយកពលករបុរសមកធ្វើការងារ ដែលប្រើកម្លាំងសុទ្ធ

អ្នកចូលរួមក្នុងឧស្សាហកម្មបៃតងហាក់មានស្មារតីយល់អំពីសង្គមច្រើន ហេតុដូច្នេះហើយជាទូទៅសកម្មភាពរបស់ពួកគេក៏មានភាពបរិយាបន្នច្រើនជាង

ធុរកិច្ចឧស្សាហកម្មបៃតងដែលដឹកនាំដោយស្ត្រី ផ្តល់លទ្ធភាពកាន់តែច្រើនដល់ស្ត្រីក្នុងជួរបុគ្គលិកធម្មតា ឬក្នុងលំដាប់ផ្នែកគ្រប់គ្រងរបស់អាជីវកម្ម

**ទន្ទឹមគ្នានេះ នៅមានឧបសគ្គមួយចំនួនដែលបន្តរាំងដល់ភាពរីកចម្រើនរបស់ស្ត្រី។**

ក្នុងការឆ្លើយទៅនឹងសំណួរថា “តើអ្វីជាឧបសគ្គដ៏ធំជាងគេក្នុងការប្រែក្លាយអាជីវកម្មរបស់អ្នកឱ្យទៅជាអាជីវកម្មបៃតង ?” សហគ្រិនបៃតងនិយាយថាថ្លៃចំណាយជាឧបសគ្គធំបំផុតសម្រាប់ពួកគេក្នុងការប្រែក្លាយអាជីវកម្មឱ្យកាន់តែបៃតង រីឯសម្រាប់សហគ្រិនធម្មតាវិញឧបសគ្គធំគឺកង្វះការយល់ដឹងអំពីរបៀបធ្វើការផ្លាស់ប្តូរទៅរកភាពបៃតង។

ឧបសគ្គផ្សេងទៀតដែលបានលើកឡើងមាន៖ លទ្ធភាពតិចតួចក្នុងរកបច្ចេកវិទ្យា, ទីផ្សារ, ដើមទុន, ការធានា, ធនធានឥណទាន, បណ្តាញ និងការផ្តល់ប្រឹក្សា -- ទាំងអស់នេះហើយធ្វើឱ្យស្ត្រីមិនអាចចាប់ផ្តើមអាជីវកម្មបៃតងរបស់ពួកគេបាន។



**៥០%**

នៃសហគ្រិនស្ត្រីក្នុងឧស្សាហកម្មបៃតងបានលើកឡើងពីការខ្វះដីធ្លីឬសិទ្ធិលើទ្រព្យសម្បត្តិដែលអាចប្រើបានជាវត្ថុបញ្ចាំ

**៨៣%**

នៃសហគ្រិនស្ត្រីក្នុងឧស្សាហកម្មបៃតងនិយាយថាគេមិនបានដឹងពីកម្មវិធីសម្រាប់ស្ត្រីដើម្បីផ្តើមអាជីវកម្មនៅក្នុងឧស្សាហកម្មនេះទេ

**៦២%**

នៃសហគ្រិនស្ត្រីនៅក្នុងឧស្សាហកម្មបៃតងបានលើកឡើងពីការលំបាកក្នុងការទទួលបានជំនាញបច្ចេកទេស

*តាមរយៈការអង្កេតអនឡាញដែលជាវិធីសាស្ត្រសម្រាប់ការវាយតម្លៃ*

ស្ថិតិតំណាងទូទាំងប្រទេសស្តីពីការចូលរួមរបស់ស្ត្រីនៅក្នុងឧស្សាហកម្មបៃតងមានតិចតួចណាស់ ឬមិនមានតែម្តង។ អាស្រ័យហេតុនេះហើយទើបមានការពិបាកក្នុងការកំណត់គោលដៅ និងត្រួសត្រាយផ្លូវសម្រាប់ធ្វើសកម្មភាពដើម្បីលើកកម្ពស់ការចូលរួមរបស់ស្ត្រី នៅពេលដែលមិនមានទិន្នន័យបន្ទាត់គោល និងខ្វះភាពច្បាស់លាស់អំពីស្ថានភាពបច្ចុប្បន្ន។

បទដ្ឋានសង្គមដែលធ្វើឱ្យខាតប្រយោជន៍, កង្វះលទ្ធភាពទៅណាមកណាដោយសេរី, ការងារថែទាំគ្មានប្រាក់កម្រៃ, វិសមភាពក្នុងទិដ្ឋភាពច្រើនបែបយ៉ាង និងកង្វះទំនុកចិត្តលើខ្លួនឯង សុទ្ធតែមានចំណែកធ្វើឱ្យស្ត្រីមិនសូវមានលទ្ធភាពក្នុងការរកបានធនធាន និងឱកាសដូចមានរៀបរាប់នៅខាងលើ។

“

ដូចអ្នកធ្លាប់ដឹងហើយ អ្នកចាំបាច់ត្រូវមានដីធ្លី ឬសំណង់អ្វីមួយ ដែលអាចដាក់ជាវត្ថុបញ្ចាំបាន។ ចុះបើអ្វីៗសុទ្ធតែនៅក្រោមឈ្មោះរបស់ប្តី តើអ្នកអាចធ្វើអ្វីកើត?

”

\- សម្រង់សម្តីរបស់អ្នកផ្តល់សម្ភាសម្នាក់



“

ប្រសិនបើខ្ញុំរវល់ប្រជុំពេញមួយថ្ងៃ ឬមួយល្ងាច តើបានអ្នកណាធ្វើកិច្ចការផ្ទះ? តើបានអ្នកណាដាំបាយល្ងាច? នេះហើយដែលបន្ទុចបង្អាក់ពួកយើងបើប្រៀបធៀបជាមួយបុរស។ ប្រុសៗគ្មានការទទួលខុសត្រូវ ឬការរឹតត្បិតបែបនេះទេ។ ពួកគេស្រណុកជាង។

”

\- សម្រង់សម្តីរបស់អ្នកផ្តល់សម្ភាសម្នាក់

## បច្ចុប្បន្ននេះការបញ្ជ្រាបយេនឌ័រក្នុងគោលនយោបាយឧស្សាហកម្មបៃតង របស់ប្រទេសកម្ពុជានៅមានដែនកំណត់។

រាជរដ្ឋាភិបាលកម្ពុជាស្ថិតក្នុងចំណោមរដ្ឋាភិបាលនាំមុខមួយចំនួនលើពិភពលោក ដែលបានបង្កើតគោលនយោបាយឧស្សាហកម្មបៃតងដំបូងគេ។ ទោះបីជាដូច្នោះក៏ដោយ ភាគច្រើននៃគោលនយោបាយទាំងនោះមិនសូវឆ្លុះបញ្ចាំងនូវការគិតគូរអំពីយេនឌ័រប៉ុន្មានទេ។

## ៧ ក្នុងចំណោម ១០

នៃគោលនយោបាយឧស្សាហកម្មបៃតងខ្វះការគិតគូរអំពីយេនឌ័រនៅក្នុងមាតិការបស់វា និងក្នុងដំណើរការដើម្បីធានាឱ្យបាននូវការចូលរួមរបស់ស្ត្រី *

## ៨ ក្នុងចំណោម ១០

នៃគោលនយោបាយឧស្សាហកម្មបៃតងមានការប្តេជ្ញាចិត្តឬគោលដៅដាក់លាក់ពាក់ព័ន្ធយេនឌ័រក្នុងកម្រិតតិចតួច ឬសឹងតែគ្មានតែម្តង *

**វិធីសាស្ត្រវាយតម្លៃ៖ ឯកសារចំនួន១០មុខក្នុងចំណោមគោលនយោបាយ, យុទ្ធសាស្ត្រ និងផែនការថ្នាក់ជាតិរបស់កម្ពុជាត្រូវបានយកមកពិនិត្យវាយតម្លៃដោយប្រើវិធីវិភាគគោលនយោបាយសំខាន់ៗដែលគាំទ្រដល់ស្ត្រី ( Feminist Critical Policy Analysis )។*

## អនុសាសន៍សម្រាប់ជំរុញការចូលរួមរបស់ស្ត្រីក្នុងសេដ្ឋកិច្ចបៃតង

បង្កើនការដឹងនិងការយល់ដឹងថាតើ "ឧស្សាហកម្មបៃតង" ជាអ្វី

កសាងសមត្ថភាពរបស់រដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់មូលដ្ឋានក្នុងការអភិវឌ្ឍ និងអនុវត្តច្បាប់ "បៃតង"

ពិនិត្យឡើងវិញនិងបង្កើតក្របខណ្ឌតាមដាន និងវាយតម្លៃជាក់លាក់មួយដែលប្រមូលផ្តុំស្ថិតិយេនឌ័រគោលដែលបែងចែកតាមភេទ និងមានទិដ្ឋភាពចម្រុះ

លើកកម្ពស់បណ្តាញសហការស និងការផ្លាស់ប្តូរដំណើរទស្សនកិច ឬកម្មវិធីនានា និងបង្កើនវត្តមានរបស់សហគ្រិនស្ត្រី

"គំរូពិតជាមានសារៈសំខាន់ណាស់។ ប្រសិនបើស្ត្រីឃើញមានគំរូកាន់តែច្រើនអំពីអ្វីដែលគេកំពុងធ្វើ នោះគេនឹងគិតថាគេអាចធ្វើតាមបាន។ មិនទាន់មានមនុស្សច្រើនដែលអាចធ្វើជាគំរូនៅឡើយទេ អញ្ចឹងហើយបានជាអ្នកមិនឃើញមានឧទាហរណ៍ដែលអាចយកទៅប្រើបានទេ។ ដូច្នេះជាថ្មីម្តងទៀត ខ្ញុំគិតថាកម្មវិធីបណ្តុះបណ្តាល ការផ្តល់ ឱវាទទាំងអស់នេះគឺជាអ្វីដែលសំខាន់ណាស់ ពីព្រោះនោះជាវិធីដែលស្ត្រីរៀបរាប់អំពីខ្លួនឯង និងមើលឃើញខ្លួនឯងថាអាចធ្វើដូច្នោះបានដូចគេឯងទៀតដែរ។"

- សម្រង់សម្តីរបស់អ្នកផ្តល់សម្ភាសម្នាក់

**បង្កើត និងអនុវត្តក្របខណ្ឌគោលនយោបាយមួយដើម្បីបញ្ចូលយេនឌ័រឱ្យកាន់តែប្រសើរថែមទៀត ទៅក្នុងគោលនយោបាយឧស្សាហកម្មបៃតងថ្មី ព្រមទាំងបញ្ជ្រាបយេនឌ័រទៅក្នុងគោលនយោបាយ និងកម្មវិធីដែលមានស្រាប់ផងដែរ។**

ជំហានទី១

បញ្ចូលការវាយតម្លៃ I ស្តីពីលក្ខណៈវិនិច្ឆ័យតាមរយៈការវិភាគគោលនយោបាយសំខាន់ៗដែលគាំទ្រដល់ស្ត្រី។*

ជំហានទី២

បញ្ចូលថែមទៀតនូវលក្ខណៈវិនិច្ឆ័យឆ្លើយតបយេនឌ័រដែលត្រូវកំណត់តាមរយៈការវិភាគកត្តាសំខាន់ៗ ដែលទ្រទ្រង់ដល់ការពង្រឹងភាពអង់អាចរបស់ស្ត្រីក្នុងឧស្សាហកម្មបៃតង។

ជំហានទី៣

បញ្ចូលការវាយតម្លៃ II ស្តីពីលក្ខណៈវិនិច្ឆ័យដើម្បីពង្រឹងគោលនយោបាយពាក់ព័ន្ធការប្តេជ្ញាចិត្តជាក់ស្តែងចំពោះសមភាពយេនឌ័រ។**

*ការវាយតម្លៃ I ស្តីពីលក្ខណៈវិនិច្ឆ័យតាមរយៈការវិភាគគោលនយោបាយសំខាន់ៗដែលគាំទ្រដល់ស្ត្រីរួមមាន៖ ការឆ្លុះបញ្ចាំងអំពីយេនឌ័ររបស់គោលនយោបាយ; ការយល់ដឹងជារចនាសម្ព័ន្ធអំពីសមភាពយេនឌ័រ; ពហុទិដ្ឋភាពសង្គម; ការបង្កើនភាពអង់អាចរបស់ស្ត្រី; ការផ្លាស់ប្តូរពហុទិដ្ឋភាពសង្គម; ការឆ្លើយតបយេនឌ័រ; និងការបញ្ចូលបរិបទកម្មនៅកម្រិតអន្តរជាតិនិងតំបន់។

**ការវាយតម្លៃ II ស្តីពីការវិភាគគោលនយោបាយសំខាន់ៗដែលគាំទ្រដល់ស្ត្រី វាយតម្លៃគុណភាពនៃការសន្និដ្ឋានរបស់គោលនយោបាយ លើការរៀបចំផែនការគោលដៅ ឬការប្តេជ្ញាចិត្ត ឬសូចនាករយេនឌ័រជាក់លាក់ និង/ឬ "ជំហានបន្ទាប់ទៀត"។

## សូមស្វែងយល់ថែមទៀតថាតើលោកអ្នកអាចគាំទ្រដល់របៀបវារៈនេះបានដោយវិធីណា!



## ទាញយករបាយការណ៍




របាយការណ៍
សម្រាប់កម្ពុជា
អង់គ្លេស | ខ្មែរ




របាយការណ៍សង្ខេប
សម្រាប់កម្ពុជា
អង់គ្លេស | ខ្មែរ




របាយការណ៍សំយោគការវាយតម្លៃតាម
ប្រទេសសម្រាប់កម្ពុជា, ប៉េរូ, សេណេហ្កាល
និងអាហ្វ្រិកខាងត្បូង អង់គ្លេស

## អំពីកម្មវិធី

អ៊ិនហ្វូក្រាហ្វិកនេះសង្ខេបខ្លឹមសារសំខាន់ៗចេញពីរបាយការណ៍មានចំណងជើងថា "ការវាយតម្លៃគោលនយោបាយពាក់ព័ន្ធការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រីក្នុងឧស្សាហកម្មបៃតង" សម្រាប់ប្រទេសកម្ពុជា។ របាយការណ៍នេះជាផ្នែកមួយនៃកម្មវិធី "ការបង្កើនភាពអង់អាចផ្នែកសេដ្ឋកិច្ចរបស់ស្ត្រីក្នុងឧស្សាហកម្មបៃតង" (EEWiGI) ដែលមានគោលដៅផ្តល់ប្រឹក្សាដល់អ្នករៀបចំគោលនយោបាយ និងអ្នកអនុវត្តន៍ លើការបង្កើតនិងការអនុវត្តក្របខណ្ឌគោលនយោបាយសម្រាប់ការច្របាច់បញ្ចូលយេនឌ័រ និងគោលនយោបាយឧស្សាហកម្មបៃតង
នៅក្នុងប្រទេសទាំងបួនដែលចូលរួមក្នុងកម្មវិធីនេះ គឺ កម្ពុជា, ប៉េរូ, សេណេហ្កាល់ និងអាហ្វ្រិកខាងត្បូង។

## របៀបធ្វើការសិក្សា

**០១**
ការពិនិត្យឯកសារមានស្រាប់
និងការពិនិត្យគោល
នយោបាយបឋម

**០២**
ការវិភាគគោលនយោបាយ
សំខាន់ៗដែលគាំទ្រដល់ស្ត្រី

(គោលនយោបាយ, យុទ្ធសាស្ត្រ
និង ផែនការ ចំនួន ១០)

**០៣**
ការប្រមូលទិន្នន័យបែបគុណភាព

សម្ភាសអ្នកផ្តល់ព័ត៌មានគោល
២៨នាក់ និងពិភាក្សា ៣លើកជា
មួយក្រុមគោល ( FGDs)

**០៤**
ការប្រមូលទិន្នន័យបែបបរិមាណ

ការអង្កេតតាមអនឡាញ
(ផ្តល់ចម្លើយ ១៦នាក់)


បើលោកអ្នកមានមតិយោបល់បន្ថែមលើឯកសារនេះ សូមសរសេរផ្ញើទៅកាន់បណ្ឌិត
Dr. Ozunimi Iti
ប្រធានគម្រោង
o.iti@unido.org